AMS
អរិយធម៌ខ្មែរ

# អរិយធម៌ពែក្ស

អរិយធម៌ពែក្ស ដែលត្រូវបានគេស្គាល់ថាជាអាណាចក្រ Achaemenid ដែលមានទំហំទឹកដីយ៉ាងធំធេង ដោយគ្រប់ដណ្ដប់លើតំបន់ជាច្រើនដែលសព្វថ្ងៃមានដូចជាប្រទេសអ៊ីរ៉ង់ ទួគី ផ្នែកខ្លះនៃអេហ្ស៊ីប និងផ្នែកខ្លះនៃប៉ាគីស្ថានជាដើម (រូបលេខ១)។[១]

មុននឹងក្លាយជាអាណាចក្រពែក្ស ពែក្សគឺជាជនជាតិដែលរស់នៅតាមតំបន់ទន្លេ Tigris ដែលស្ថិតនៅក្បែរ មេសូប៉ូតាមី និងអេហ្ស៊ីប។ នៅស.វ.ទី៥ មុនគ.ស. ពែក្សបានក្លាយជារដ្ឋមួយ និងគ្រប់គ្រងដោយស្ដេច Cyrus និងក្រោយមកទៀតក្រោមការដឹកនាំរបស់ស្ដេច Darius ទី១( ឆ្នាំ៥២២-៤៨៦មុនគ.ស)[២] ត្រូវបានគេដឹងថារដ្ឋមួយនេះបានក្លាយជាអាណាចក្រពែក្សដែលមានវិសាលភាពទឹកដីធំធេង ពីតំបន់ទន្លេសមុទ្រមីឌីទែរ៉ាណេ រហូតដល់ទន្លេ នីលនៃប្រទេសអេហ្ស៊ីប។[៣]

នៅក្នុងប្រវត្តិសាស្ត្រពិភពលោក ពែក្សគឺជាអាណាចក្រដែលបានបង្កើតនូវផ្លូវទំនាក់ទំនងពាណិជ្ជកម្មដោយភ្ជាប់ពី ទ្វីបអាហ្វ្រិច ទៅ អ៊ឺរ៉ុប និងអាស៊ី[៤] ដែលចាប់ផ្ដើមពី តំបន់សំខាន់គឺ Persepolis (អ៊ីរ៉ាក់) និង Susa (អ៊ីរ៉ាក់) ដោយភ្ជាប់ជាមួយនឹងបណ្ដាញផ្លូវជាច្រើនទៀតរហូតដល់តំបន់ទន្លេ ឥណ្ឌូស។[៥] ជនជាតិពែក្សបុរាណបានបង្កើតសិល្បៈរបស់ខ្លួនទៅតាមទម្រង់ផ្សេងៗដែលបានរកឃើញនៅតាមតំបន់ជាច្រើននៃអរិយធម៌នេះ រួមមានវត្ថុសិល្បៈ ពីការស្មូនដីធ្វើជា គ្រឿងអលង្ការ រូបចម្លាក់អំពីថ្ម លោហៈធាតុ(កងដៃមាស) និងអំពីដីឥដ្ឋជាដើម(រូបលេខ២-៣)។ ជាពិសេសសំណង់ស្ថាបត្យកម្មសំខាន់ៗនៃអរិយធម៌មួយនេះ ដែលមានដូចជា Persepolis និង Susa។ Susa គឺជារាជធានីដំបូងនៃអាណាចក្រពែក្ស ដែលកសាងដោយស្ដេច Darius ទី១ នៅស.វ.ទី៥មុនគ.ស.។ Susa ត្រូវបានគេដឹងថាជារាជធានីសំខាន់ ដោយភ្ជាប់ជាមួយនឹងសាសនាដែលជនជាតិពែក្សបុរាណជឿលើអទិទេព

---

[១] https://www.nationalgeographic.org :Persian Empire

[២] Pierre BRIANT, 1999, p.12

[៣] *Ibid*

[៤] https://www.history.com: ancient middile east /persian empire

[៥] Matt Waters , 2014 p.6

អត្ថបទដោយ៖ អេង តុលា

Ahura Mazda ហៅថា សាសនា Zoroastrianism ដែលជនជាតិពែក្សគោរពប្រតិបត្តិមុនការចូលមកដល់នូវសាសនា អ៊ីស្លាម (រូបលេខ២)។[៦]

យោងតាមការស្រាវជ្រាវតាមបែបបុរាណវិទ្យាបានបង្ហាញថាតំបន់ Susa គឺមានតឹកតាងប្រវត្តិសាស្ត្រតាំងពី សម័យបុរេប្រវត្តិ រហូតដល់សម័យប្រវត្តិសាស្ត្រ ហើយក៏ឃើញមានសិល្បៈនៃអរិយធម៌ពីរចូលគ្នា គឺសិល្បៈនៃអរិយធម៌មេសូប៉ូតាមី និងសិល្បៈពែក្ស(រូបលេខ៥-៦)។[៧] រីឯ Persepolis វិញ គឺជារាជធានី សំខាន់បន្ទាប់ពី Susa ដែលត្រូវបានកសាងដោយស្តេច Darius ទី ១ នៅឆ្នាំ ៥១៨មុនគ.ស.។[៨] Persepolis ត្រូវបានកសាងនៅជើងភ្នំ Kuhe Rahmat ភាគខាងត្បូងនៃប្រទេសអ៊ីរ៉ង់ ដែលសិល្បៈនៃការឆ្លាក់ និងរបៀបរៀបចំគឺទទួលឥទ្ធិពលពីអរិយធម៌មេសូប៉ូតាមី (រូបលេខ៧-៨)។[៩] ជាពិសេសចម្លាក់រូបលើសសរដែលឃើញមានរូបខ្លួនជាសត្វគោ និងក្បាលជាសត្វឥន្ទ្រី ដែលហៅថា Griffin។ Griffin ត្រូវបានគេដឹងថាជា និមិត្តសញ្ញានៃរាជធានីរបស់អាណាចក្រពែក្សបុរាណ (រូបលេខ៩)។[១០]

អាណាចក្រពែក្សត្រូវបានធ្លាក់ចុះ បន្ទាប់ពីការលុកលុយពីអាណាចក្រក្រិចដែលដឹកនាំដោយ Xerxes ទី១ នៅស.វ.ទី៤មុនគ.ស. និងជាចុងក្រោយអាណាចក្រពែក្សត្រូវបានដួលរលំដោយការដឹកនាំ Alexander the great នៅស.វ.ទី៣មុនគ.ស.។[១១] តាមរយៈសំណង់ស្ថាបត្យកម្ម សិល្បៈដែលបានបន្សល់ពីអរយិធម៌ពែក្ស អ្នកស្រាវជ្រាវបានបង្ហាញថា អរិយធម៌នៃអាណាចក្រពែក្សមានឥទ្ធិពលខ្លាំងក្លា និងរុងរឿងជាងគេនៅតំបន់សមុទ្រមីឌីទែរ៉ាណេនៅអំឡុងស.វទី២មុនគ.ស.[១២] ហើយអរិយធម៌នេះកកើតឡើងនៅប្រមាណជាង ៥០០ឆ្នាំមុនគ.ស.។[១៣] សព្វថ្ងៃនេះវត្ថុសិល្បៈជាច្រើននៃអរិយធម៌ពែក្សបុរាណត្រូវបានដាក់តាំងបង្ហាញនៅតាមសារមន្ទីរបរទេស ជាពិសេសនៅសារមន្ទីរទីក្រុងឡុង(British museum) និងនៅសារមន្ទីរល្វូរ (Louvre museum) ប្រទេសបារាំង។

---

៦ https://www.history.com: Zoroastrianism

៧ https://whc.unesco.org: Susa

៨ https://whc.unesco.org :Persepolis

៩ *Ibid*

១០ https://www.history.com: ancient middile east /persian empire

១១ https://www.nationalgeographic.org: Empire persian

១២ https://www.history.com: ancient middile east /persian empire

១៣ https://www.nationalgeographic.org: Persian Empire




រូបលេខ១៖ ផែនទីនៃវិសាលភាពអាណាចក្រពែក្សបុរាណ

ប្រភព៖ https://www.history.com



រូបលេខ២៖ កងដៃអំពីមាស និងមានរូបចម្លាក់ Griffin

ប្រភព៖ British Museum

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៣៖ រូបអំពីមាស

ប្រភព៖ British Museum



រូបលេខ២៤៖ រូបចម្លាក់អទិទេព Ahura Mazda នៅ Susa

ប្រភព៖ [File:AhuraMazda-Relief.jpg - Wikimedia Commons]



រូបលេខ៥៖ រូបថតពីលើ Susa

ប្រភព៖ https://whc.unesco.org




រូបលេខ៦៖ ផ្ទាំងចម្លាក់នៅ Susa ដែលបច្ចុប្បន្នតាំងបង្ហាញនៅសារមន្ទីរ ល្វូវ

ប្រភព៖ Babak Tafreshi

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៧៖ Persepolis

ប្រភព៖ www.history.com



រូបលេខ២៨៖ Persepolis

ប្រភព៖ www.history.com



រូបលេខ២៨៖ Griffin

ប្រភព៖ https://www.history.com

## ឯកសារយោង

Matt Waters
    2014 History of ancient Persia
Pierre BRIANT
    1999 Histoire et civilisation du monde achéménide et de l’empire d’Alexandre

**Website**

https://www.history.com: ancient middile east /persian empire
https://www.history.com: Zoroastrianism
https://whc.unesco.org: Susa
https://whc.unesco.org :Persepolis
https://www.nationalgeographic.org: Empire persian

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION